00555082


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ

Pre-Trial Chamber
Chambre Préliminaire


ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 14 / 07 / 2010
ម៉ោង (Time/Heure) : 10 : 45
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

លេខ/No: D365/2/16

*តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់*
*ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម*
*ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

| | |
|---|---|
| **សំណុំរឿងលេខ:** | ០០២/១៩-០៩-២០០៧-**អវកត/កសចស(អបជ៦៧)** |
| **ចំពោះមុខ៖** | **ចៅក្រម ប្រាក់ គឹមសាន** **ប្រធាន** |
| | **ចៅក្រម Rowan DOWNING** |
| | **ចៅក្រម ន៉ីយ ថុល** |
| | **ចៅក្រម Catherine MARCHI-UHEL** |
| | **ចៅក្រម ហួត វុទ្ធី** |
| **កាលបរិច្ឆេទ៖** | ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១០ |

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 14 / 07 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

**សាធារណៈ:**

# សាលដីកាស្តីពីការពិចារណាឡើងវិញ នៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតនៅលើសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមនៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង

---

| **<u>សហព្រះរាជអាជ្ញា</u>** | **<u>ជនត្រូវចោទ</u>** |
|---|---|
| លោកស្រី ជា លាង | លោក អៀង សារី |
| លោក Andrew CAYLEY | លោក នួន ជា |
| លោក យ៉េត ចរិយា | លោក ខៀវ សំផន |
| លោក William SMITH | |
| លោក សេង ប៊ុនឃាង | |

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C * C.E.T.C

លោក Partirck BAUDOUIN

លោកស្រី ជេត វណ្ណលី

លោក ពេជ អង្គ

លោក Julien RIVET

លោក Pascal AUBOIN

លោក យ៉ុង ផានិត

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អវតក") បានទទួល "បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងទៅនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីការសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង" ("បណ្តឹងឧទ្ធរណ៍")[១] ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១០ ដែលបានដាក់ដោយសហព្រះរាជអាជ្ញាប្រឆាំងនឹង"ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង" ("ដីកាដែលរងការជំទាស់លើកទី១")[២] ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១០។ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដែលរងការជំទាស់លើកទី១ ដើម្បីឆ្លើយតបទៅនឹង "សំណើរបស់សហព្រះរាជអាជ្ញាសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែម ទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ("សំណើសុំ")[៣] ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០។

អង្គបុរេជំនុំជម្រះក៏បានទទួលសារណាតបផ្ទាល់មាត់បន្ថែមទៀត ឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងដោយក្រុមមេធាវីការពារក្តីរបស់ជនត្រូវចោទ អៀង សារី, ខៀវ សំផន និង នួន ជា ដែលបានលើកឡើងនៅក្នុងសវនាការកាលពីថ្ងៃទី២៦ ដល់ ២៧ ខែឧសភា ឆ្នាំ២០១០ កន្លងទៅនេះ[៤]។ អង្គបុរេជំនុំជម្រះក៏

---

[១] សារណាបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជា ឆ្លើយតបទៅនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្តីពីការដាក់ឯកសារបន្ថែមទៅក្នុងសំណុំរឿង ដែលជួយបញ្ជាក់អំពីការដឹងឮរបស់ជនត្រូវចោទពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១០, ឯកសារលេខ D365/2/1 ("បណ្តឹងឧទ្ធរណ៍")។

[២] ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើរបស់សហព្រះរាជអាជ្ញា សុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១០ ឯកសារលេខ D365/1 ("ដីកាដែលរងការជំទាស់លើកទី១")។

[៣] សំណើរបស់សហព្រះរាជអាជ្ញា សុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០, ឯកសារលេខ D365 ("សំណើសុំ")។

[៤] ឯកសារលេខ D365/2 ប្រតិចារឹកសវនាការ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១០, ERN 00531441-00531487 និងឯកសារលេខ D365/2 ប្រតិចារឹកសវនាការ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១០ ERN 00531583-00531634។

បានទទួល "សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាបន្ថែមទៀត ដោយអនុលោមតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០" ("សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាសុំឱ្យពិចារណាឡើងវិញ")[៥] ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១០២០ ប្រឆាំងទៅនឹង "ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការឆ្លើយតបទៅនឹងសាលដីការបស់អង្គបុរេជំនុំជម្រះសម្រេចទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើរបស់សហព្រះរាជអាជ្ញា សុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿងដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង" ("ដីកាដែលរងការជំទាស់លើកទី២")[៦] ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១០។

អង្គបុរេជំនុំជម្រះក៏បានទទួលចម្លើយតបដែលបានដាក់ទាន់ពេលវេលា ឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាស្នើសុំឱ្យពិចារណាឡើងវិញ "ចម្លើយតបចំពោះសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមសាលដីការបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០"[៧] ដែលដាក់ដោយមេធាវីការពារក្តីរបស់ នួន ជា ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១០ ("ចម្លើយតបរបស់ នួន ជា") និងចម្លើយតបរបស់ក្រុមមេធាវីការពារក្តី លោក ខៀវ សំផន ទៅនឹងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញា ដោយអនុលោមទៅតាមដីកាសម្រេចរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ ("ចម្លើយតបរបស់ ខៀវ សំផន") ("ចម្លើយតបរបស់ ខៀវ សំផន")[៨]។

---

[៥] សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ព្រះរាជអាជ្ញា ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១០ ឯកសារលេខ D365/2/12, ("សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យពិចារណាឡើងវិញ") អនុលោមតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០។

[៦] ដីកាសម្រេចឆ្លើយតបទៅនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១០ ("ដីកាដែលរងការជំទាស់លើកទី២)។

[៧] ចម្លើយតបចំពោះសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ស្របតាមសាលដីការបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ ដែលបានដាក់នៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១០ ឯកសារលេខ D365/2/13 ("ចម្លើយតបរបស់ នួន ជា")។

[៨] ចម្លើយតបចំពោះសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ស្របតាមសាលដីការបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ ដែលបានដាក់នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១០ ឯកសារលេខ D365/2/15 ("ចម្លើយតបរបស់ ខៀវ សំផន")។



C.E.T.C * CHAMBRE PRÉLIMINAIRE * PRE-TRIAL CHAMBER

អង្គបុរេជំនុំជម្រះបានចេញ "សាលដីកាសម្រេចទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត អំពីសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿងដែលនឹងជួយបញ្ជាក់ការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០" ("សាលដីកាចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០")[៩]។ នៅក្នុងសាលដីកាចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ នេះ អង្គបុរេជំនុំជម្រះបានពិចារណាថា បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន និងបានណែនាំឲ្យសហចៅក្រមស៊ើបអង្កេតកែតម្រូវចំណុចខ្វះខាតមួយចំនួន នៅក្នុងដីកាដែលរងការជំទាស់លើកទី១[១០]។

អង្គបុរេជំនុំជម្រះបានសម្រេចនៅបញ្ញត្តិចុងក្រោយលើបណ្តឹងឧទ្ធរណ៍ ដែលអង្គបុរេជំនុំជម្រះប្រកាសនៅពេលនេះ។ អង្គបុរេជំនុំជម្រះនឹងចេញសេចក្តីសម្រេចដែលមានសំអាងហេតុ សម្រាប់បណ្តឹងឧទ្ធរណ៍នេះក្នុងពេលវេលាសមស្រប។

---

[៩] សាលដីកាសម្រេចទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត អំពីសំណើសុំដាក់ឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ ឯកសារលេខ D365/2/10 ("សាលដីកាចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០")។

[១០] សាលដីកាចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០។

**ដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទថា:-**

១. **តម្កល់**ការបដិសេធមួយផ្នែកនៃសំណើសុំ នៅក្នុងដីកាសម្រេចដែលរងការជំទាស់លើកទី១ និងដីកាសម្រេចដែលរងការជំទាស់ទី២ និង

២. **បដិសេធ**បណ្តឹងឧទ្ធរណ៍នេះចោល។

ដោយអនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះបិទផ្លូវតវ៉ា។

ភ្នំពេញ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១០

**អង្គបុរេជំនុំជម្រះ** **ប្រធាន**

**Rowan DOWNING** **នំយ ថុល** **Catherine MARCHI-UHEL** **ហួត វុទ្ធី** **ប្រាក់ គឹមសាន**

*សាលដីកាស្តីពីការពិចារណាឡើងវិញ ទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿងដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង។*